រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ១៤២ គរ.ប្រក
## អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd
## ធ្វើប្រតិបត្តិការរុករកធនធានរ៉ែនៅតំបន់ក្រវ៉ា ខេត្តកំពង់ធំ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែនៅតំបន់ក្រវ៉ា ខេត្តកំពង់ធំ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៤
- បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតស្វែងរុករកធនធានរ៉ែរបស់ក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៤

### សំរេច

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. មានអាស័យដ្ឋានផ្ទះលេខ ៣២០ មហាវិថីកម្ពុជាក្រោម រាជធានីភ្នំពេញធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែនៅតំបន់ក្រវ៉ា ខេត្តកំពង់ធំ លើផ្ទៃដី ១៩៨ គីឡូម៉ែត្រក្រឡា មានកូអរដូណេដូចតទៅ ÷

| ចំណុច | ខ្សែរយៈបណ្តោយ | ខ្សែរយៈទទឹង |
|---|---|---|
| A | 105° 11'37"E | 12° 31'44"N |
| B | 105° 21'32"E | 12° 31'44"N |
| C | 105° 21'32"E | 12° 25'16"N |
| D | 105° 11'37"E | 12° 25'16"N |

**ប្រការ ២ :** ក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ត្រូវដំណើរការងារស្វែងរុករកធនធានរ៉ែ លើផ្ទៃដីដែលបានកំណត់នេះដោយធានាអនុវត្តតាមបច្ចេកទេសភូគព្ភសាស្ត្រ ។

**ប្រការ ៣** : ប្រកាសនេះមានតំលៃដល់ថ្ងៃទី ២៣ មីនា ១៩៩៨ ។ ផុតកំណត់នេះ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំការអនុញ្ញាតិធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានល័ក្ខខ័ណ្ឌ ។

**ប្រការ ៤** : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ - រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច ប្រធានមន្ទីរនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត កំពង់ធំ និង ប្រធានក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ត្រូវទទួលអនុវត្ត ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ពូ សុធីរៈ**

* * *

# ៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

# ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០៧២/៩៦ ពប.មពប្រក**

**អនុញ្ញាតអោយឧស្សនាវដ្តីឈ្មោះ រះណសិរ្ស ២ ឆ្នូ**

**បោះពុម្ពចែកផ្សាយឡើងវិញ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស